**ចម្លើយមកពីសាវក**



**ដោយអែលឌើរ
ដាវីឌ អេ បែដណា**
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# តើពួកសាវកធ្វើអ្វីខ្លះ ?



ពួកសាវកគឺជាអ្នកបម្រើរបស់ព្រះអម្ចាស់ ។ ពួកគេធ្វើដំណើរទៅសួរសុខទុក្ខសមាជិកសាសនាចក្រនៅជុំវិញពិភពលោក ។

គ្រាដំបូងដែលខ្ញុំបានធ្វើដំណើរក្នុងនាមខ្ញុំជាសាវក នោះខ្ញុំបានជួបនឹងបុរសម្នាក់ដែលមានការលំបាកក្នុងការរស់នៅតាមច្បាប់នៃពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ។ ខ្ញុំបានប្រាប់គាត់ថា « ព្រះអម្ចាស់បានបញ្ជូនខ្ញុំមកទីនេះ ឲ្យប្រាប់ដល់អ្នកនូវសារលិខិតយ៉ាងសាមញ្ញមួយ ៖ ‹ អ្នកអាចធ្វើតាមវាបាន ។ ខ្ញុំសន្យាថា ព្រះនឹងជួយអ្នកនៅពេលអ្នកប្រឈមមុខនឹងឧបសគ្គនេះ › » ។

តើព្រះអម្ចាស់បញ្ជូនសាវកម្នាក់នៃពួកសាវកដប់ពីរនាក់ឲ្យធ្វើដំណើរចម្ងាយពាក់កណ្ដាលពិភពលោក ដើម្បីគ្រាន់តែជួយមនុស្សម្នាក់ឬ ? ចម្លើយគឺថា *មែនហើយ* ។ ទ្រង់ធ្វើបែបនេះគ្រប់ពេលទាំងអស់ ។ ■

*ដកស្រង់ចេញពីការចាក់ផ្សាយកម្មវិធីជួបមុខគ្នាផ្ទាល់ទូទាំងពិភពលោករបស់អែលឌើរ និង ស៊ីស្ទើរបែដណា ។*

រូបគំនូរដោយ ស្កត ព្រៀ